**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**

# សុន្ទរកថា
## ឯកឧត្តមទេសរដ្ឋមន្ត្រី អៀង មូលី ប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
## ថ្លែងក្នុងឱកាសបិទ
## សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ២០២១ និងលើកទិសដៅ ឆ្នាំ២០២២ របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

**ថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០២១**
**នៅអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងតាមបណ្តាញវីដេអូ កម្មវិធីZoom**

**ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ដែលកំពុងមានវត្តមានដ៏ឧត្តុង្គឧត្តម និងតាមបណ្តាញវីដេអូ កម្មវិធីZoom នាពេលនេះ!**

ឆ្លងតាមបទបង្ហាញមួយចំនួនស្តីពី វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជាអាទិភាពចម្បងនានា រួមជាមួយនឹងសមិទ្ធផល ជាពិសេសមេរៀនជាបទពិសោធន៍ល្អៗ ដែលបានមកពីការអនុវត្តន៍របស់សមាជិក សមាជិកា អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍នៅទូទាំងប្រទេស នៅក្នុងអង្គសន្និបាតនាព្រឹកនេះ តាងនាមអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវការអបអរសាទរ និងកោតសរសើរដ៏ស្មោះស្ម័គ្រចំពោះសមាជិក សមាជិកានៃអង្គសន្និបាត និងនៅទូទាំងប្រទេស ដែលបានខិតខំប្រឹងប្រែងយ៉ាងសកម្មចូលរួមប្រយុទ្ធនឹងមេរោគអេដស៍ និងជំងឺអេដស៍ទទួលបានជោគជ័យជាបន្តបន្ទាប់គួរជាទីមោទនៈ។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី នាងកញ្ញា!*

សមិទ្ធផល និងកត្តាជោគជ័យ ដែលយើងទាំងអស់គ្នាទទួលបាន គឺពិតជាលទ្ធផលនៃការចូលរួមចំណែក របស់សមាជិក សមាជិកាអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ដែលជាក្រសួង ស្ថាប័ន រាជធានី ខេត្ត របស់រាជរដ្ឋាភិបាលកម្ពុជា ដៃគូអភិវឌ្ឍន៍ អង្គការសង្គមស៊ីវិល បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បណ្តាញក្រុមប្រឈមមុខខ្ពស់នឹងការចម្លងមេរោគអេដស៍។ល។ រួមជាមួយនឹងការប្តេជ្ញាចិត្តដ៏មោះមុត និងត្រឹមត្រូវផ្នែកនយោបាយពីថ្នាក់ដឹកនាំកំពូលរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកប

គតិបណ្ឌិតដ៏ខ្ពង់ខ្ពស់ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និងការគាំទ្រដោយមិនចេះនឿយហត់ផ្នែកសេវាគាំពារសង្គមពី **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុនសែន ប្រធានកាកបាទក្រហមកម្ពុជា**។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ក្នុងនាមជាប្រធានអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ឆ្លងតាមការពិភាក្សាយ៉ាងសកម្ម នៅក្នុងអង្គសន្និបាតនាពេលនេះ ខ្ញុំសូមចូលរួមចំណែកផ្តល់នូវអនុសាសន៍មួយចំនួនដូចខាងក្រោម ៖

១. យើងត្រូវជានាឱ្យបាននូវចីរភាពនៃការឆ្លើយតបទៅនឹងមេរោគអេដស៍ និងជំងឺអេដស៍ ដោយបង្កើត ឬធ្វើបច្ចុប្បន្នភាព និងដំណើរការកិច្ចប្រជុំគណៈកម្មាធិការប្រយុទ្ធនឹងជំងឺអេដស៍គ្រប់លំដាប់ថ្នាក់ ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពិសេស ក្នុងឃុំ សង្កាត់ទាំងអស់នៅទូទាំងប្រទេស។

២. យើងត្រូវខិតខំធ្វើសមាហរណកម្មកម្មវិធីបង្ការ ថែទាំ និងព្យាបាលអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ ទៅក្នុងប្រព័ន្ធសុខាភិបាល ដើម្បីទទួលបាននូវការឆ្លើយតបប្រកបដោយប្រសិទ្ធភាព និងចីរភាព។

៣. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ចូលរួម និងជំរុញគោលនយោបាយ និងក្របខ័ណ្ឌច្បាប់សំខាន់ៗរបស់រាជរដ្ឋាភិបាល ពាក់ព័ន្ធនឹងការរៀបចំ និងប្រើប្រាស់ថវិកាថ្នាក់ក្រោមជាតិ ជាពិសេសរដ្ឋបាល ឃុំ សង្កាត់។

៤. អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ លើកទឹកចិត្ត និងចូលរួមជាមួយថ្នាក់ដឹកនាំមូលដ្ឋាន ដើម្បីម្ចាស់ការក្នុងការឆ្លើយតបនឹងមេរោគអេដស៍ និងជំងឺអេដស៍នៅក្នុងសហគមន៍ តាមរយៈការកសាងសមត្ថភាពខ្លួន និងការបង្កើតបរិយាកាសអំណោយផលសមស្របនានា។

៥. យើងទាំងអស់គ្នាពង្រឹងគោលនយោបាយប្រើប្រាស់ស្រោមអនាម័យ១០០% ដោយណែនាំឱ្យរក្សាស្រោមអនាម័យនៅគ្រប់ទីកន្លែង និងគ្រប់ពេលវេលា តាមតម្រូវការប្រកបដោយគុណភាពខ្ពស់ និងបន្តលើកទឹកចិត្តដល់ក្រុមយុវវ័យដែលរួមភេទដូចគ្នា ឱ្យធ្វើការរួមភេទដោយសុវត្ថិភាព និងឱ្យទៅពិនិត្យឈាមរកមេរោគអេដស៍ និងប្រើប្រាស់កម្មវិធីបង្ការនានាបានជាប់ជាប្រចាំ។

៦. អង្គសន្និបាតសូមអំពាវនាវដល់អង្គការជាតិ អន្តរជាតិ សង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ វិស័យឯកជន បណ្តាញអ្នកផ្ទុកមេរោគអេដស៍ និងជំងឺអេដស៍ បន្តចូលរួមជាមួយអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ ថែមទៀត តាមគ្រប់រូបភាព ទាំងកម្លាំងកាយ ប្រាជ្ញាស្មារតី ទាំងសម្ភារ និងថវិកា ដើម្បីស្វែងរកយុទ្ធសាស្ត្រថ្មីៗបន្ថែមទៀត និងពង្រីកអន្តរាគមន៍ប្រយុទ្ធនឹងជំងឺអេដស៍ ឱ្យឈានទៅសម្រេចបាននូវអត្រាគ្របដណ្តប់លើក្រុមគោលដៅ និងក្រុមប្រជាជនគន្លឹះដែលជាក្រុមប្រឈមមុខខ្ពស់។

*ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា!*

ខ្ញុំមានសង្ឃឹមថា អនុសាសន៍ទាំង៦ចំណុចខាងលើនេះ នឹងអាចយកទៅប្រើប្រាស់ជាចលករក្នុងការអនុវត្តគម្រោងផែនការសកម្មភាពជាតិទូលំទូលាយ និងពហុវិស័យឆ្លើយតបទៅនឹងការរាលដាលមេរោគអេដស៍ និងជំងឺអេដស៍ក្នុងឆ្នាំខាងមុខឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរសព្ធសាធុការ ជូនអង្គសន្និបាតទាំងមូល សូមឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ភ្ញៀវជាតិ និងអន្តរជាតិទាំងអស់ ទទួលបាននូវសុខភាពល្អ និងសម្រេចបាននូវជោគជ័យថ្មីៗបន្ថែមទៀត នាឆ្នាំខាងមុខនិងសូមប្រកាសបិទ “**សន្និបាតបូកសរុបលទ្ធផលការងារប្រចាំឆ្នាំ ២០២១ និងលើកទិសដៅឆ្នាំ២០២២របស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍**” ចាប់ពីពេលនេះតទៅ។

***សូមអរគុណ។***